

# វគ្គបណ្តុះបណ្តាលអំពី
# ល្បែងសេរី



ENFANTS & DEVELOPPEMENT

CHEMINS D'ENFANCES

# រៀបចំដោយៈ អ្នកស្រី ប៊ួយ សុផណ្ណា

## ជំនួយការថ្នាក់ខ្ពស់ក្នុងកម្មវិធីល្បែងសេរី



# វត្ថុបំណង

1. សិក្ខាកាមប្រាប់បាន និងយល់ច្បាស់អំពីនិយមន័យរបស់ល្បែងសេរី។
2. សិក្ខាកាមរៀបចំល្បែងទៅតាមប្រភេទទាំង៤របស់ល្បែងសេរីបាន(ចំណាត់ថ្នាក់ESAR) តាមរយៈការណែនាំរបស់គ្រូ និងតាមការអនុវត្តជាក់ស្តែង។
3. យល់ច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកដឹកនាំសកម្មភាព នៅពេលសិក្សាល្បែងសេរី។



# ល្បែងសេរី និងកុមារតូច

១.ហេតុអ្វីបានជាមានការលើកទឹកចិត្តឱ្យមាន ការអនុវត្តល្បែងសេរី ?

ការបញ្ចូលល្បែងសេរី ក្នុងសកម្មភាពនៅមត្តេយ្យសិក្សា ឆ្លើយតបទៅនឹងគោលបំណងជាច្រើន :

- តម្រូវការលេងរបស់កុមារគ្រប់រូប
- ការគោរពសិទ្ធិកុមារដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល
- ការអភិវឌ្ឍសមត្ថភាព និងបំណិនរបស់កុមារ
- ការផ្សារភ្ជាប់គ្នាយ៉ាងល្អរវាងសាលារៀន និងជីវិតក្នុងសង្គម។



# ការចូលរួមលេងល្បែង: សិទ្ធិមួយរបស់កុមារ

ល្បែងជាផ្នែកមួយនៃសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិកុមារ ហើយត្រូវបានចុះហត្ថលេខាដោយរាជរដ្ឋាភិបាលប្រទេសកម្ពុជានៅឆ្នាំ ១៩៩២។

មាត្រា 31:

1. រដ្ឋដែលជាភាគីទាំងឡាយ ទទួលស្គាល់ថាកុមារមានសិទ្ធិសម្រាកនិង លំហែ ចំណាយពេលលេងល្បែង និងធ្វើសកម្មភាពច្នៃប្រឌិតផ្ទាល់ខ្លួនតាមអាយុ និងចូលរួមដោយសេរីក្នុងជីវិតវប្បធម៌ និងសិល្បៈ។
2. រដ្ឋដែលជាភាគីទាំងឡាយ គោរព និងជួយឲ្យកុមារមានសិទ្ធិចូលរួមយ៉ាងពេញលេញក្នុងជីវិតវប្បធម៌ និងសិល្បៈ ហើយលើកទឹកចិត្តការរៀបចំស្របទៅតាមចំណង់ចិត្តដែលជាមធ្យោបាយល្អប្រសើរមួយ ដែលធ្វើឲ្យត្រូវនឹងការលំហែ សកម្មភាពច្នៃប្រឌិត សិល្បៈ និងវប្បធម៌ ក្នុងល័ក្ខខ័ណ្ឌសមភាព។



# ល្បែងៈ ឧបករណ៍នៃការអភិវឌ្ឍរបស់កុមារ

១. តើកុមារត្រូវការអភិវឌ្ឍន៍ផ្នែកអ្វីខ្លះ?

២. ហេតុអ្វីបានជាគេនិយាយថា ល្បែងជាឧបករណ៍នៃការអភិវឌ្ឍរបស់កុមារ?



# ការអភិវឌ្ឍរាងកាយ និងចិត្តចលភាព

| ការអភិវឌ្ឍន៍ ចន្លោះពី ៣ ទៅ ៦ឆ្នាំ ក្នុងវិស័យនេះ | ផលប្រយោជន៍របស់ល្បែង |
| --- | --- |
| • នៅអាយុ៣ឆ្នាំ កុមារម្ចាស់ការលើការដើរ ហើយជាបណ្តើរៗ កុមារម្ចាស់ការលើការរត់ និងការលោតផងដែរ។ កុមាររៀនធ្វើការប្រថុយ ដែលគេវាស់ស្ទង់បានដោយខ្លួនគេ។ ការអភិវឌ្ឍរាងកាយ និងចិត្តចលភាព ត្រូវតែគាំទ្រដោយសកម្មភាពចលករ ឬល្បែង ដែលបញ្ចូលក្នុងការសម្របសម្រួលដងខ្លួន។ | • ល្បែងចលករមួយចំនួន អភិវឌ្ឍការសម្របសម្រួលចលនាសរុប ចលនាតូច លំនឹង និងកម្លាំង។ ល្បែងផ្តល់លទ្ធភាពឲ្យកុមារស្គាល់រាងកាយ និងសមត្ថភាពរបស់គេៈ ដូចជារបៀបរត់ លោតជើងមួយ និងល្បែងលេងបាល់។ |

# ការអភិវឌ្ឍរាងកាយ និងចិត្តចលភាព (ត)

- កុមាររកឃើញនូវ វិញ្ញាណទាំងប្រាំ និងរៀនស្គាល់វិញ្ញាណនោះច្បាស់។
- ល្បែងវិញ្ញាណ អភិវឌ្ឍ ការរុករក ចំណេះដឹង និង ភាពម្ចាស់ការលើ វិញ្ញាណ (ការឮ ការឃើញ ការ ប៉ះ ការដឹងក្លិន ការដឹងរសជាតិ) ការដឹងស្គាល់ ដោយវិញ្ញាណ និង ការសម្របសម្រួលចក្ខុ-ចលករ (ឧៈ ការសម្របសម្រួលរវាងភ្នែកនិងដៃ ភ្នែកនិង ជើងក្នុងសកម្មភាព ដែលចាំបាច់ ត្រូវតម្រង់ បាញ់ វង់ ។ល។ )



# ការអភិវឌ្ឍក្ដីស្រលាញ់ និងសង្គម

## ការអភិវឌ្ឍចន្លោះពី ៣ ទៅ ៦ឆ្នាំ ក្នុងវិស័យនេះ

- ចន្លោះ ៣ ទៅ ៦ឆ្នាំ កុមារអភិវឌ្ឍសញ្ញាណ នៃ អត្តសញ្ញាណរបស់គេ (អាយុ ភេទ លក្ខណៈពិសេស) ដោយប្រៀបធៀបខ្លួនគេទៅនឹង អ្វីដែលនៅជុំវិញគេ។ គេមានការយល់កាន់តែច្បាស់ពីអ្វីជាខ្លួនគេ និងអ្វីមិនមែនជារបស់ខ្លួន ពីអ្វីដែលគេមាន និងអ្វីដែលគេមិនមាន។

## ផលប្រយោជន៍របស់ល្បែង

- នៅវ័យនេះល្បែងដើរតួមានសារសំខាន់ណាស់ក្នុងការជួយកុមារឲ្យកំណត់អត្តសញ្ញាណរបស់គេ។



# ការអភិវឌ្ឍក្តីស្រលាញ់ និងសង្គម (ត)

- កុមារតូច មានចំណុចគោល និងបទពិសោធន៍បង្អែកផ្ទាល់ខ្លួនគេ។ កុមារផ្តោតអារម្មណ៍មកលើខ្លួនឯងនិងត្រៀមខ្លួនចំពោះអ្នកផ្សេង និងវត្ថុផ្សេង។ កុមារគ្រាន់តែអាចយល់ថាអ្នកផ្សេង និងវត្ថុទាំងឡាយមានជីវិតមួយ អារម្មណ៍និងប្រតិកម្ម ប្លែកពីអារម្មណ៍និងប្រតិកម្មរបស់គេ។ គេមិនទាន់បើកទូលាយទៅលើការយល់ដឹងរបស់អ្នកផ្សេងទេ។ ឧទាហរណ៍កុមារគិតថាដុំគ្រួសអាចមានប៉ាមួយ និងម៉ាក់មួយ មេឃអាចយំ ព្រះអាទិត្យ ឬផ្ទះអាចមានមុខដូចក្នុងគំនូររបស់គេ ព្រះ អាទិត្យ "ចិត្តល្អ" ព្រោះ ព្រះអាទិត្យកម្តៅគេ តុ"ចិត្តអាក្រក់" ទង្គិចគេ។ គេសង្កេតឃើញក្នុងវ័យនេះ ជម្លោះមានញឹកញាប់ ប៉ុន្តែមានរយៈពេលខ្លីណាស់។ កុមារត្រូវការឱកាសដើម្បីធ្វើអំពើជាមួយអ្នកផ្សេង និងសម្រួល ការចូលក្នុងសង្គមរបស់គេ។
- សកម្មភាពទៅវិញទៅមកក្នុងល្បែងសេរីបង្រៀន កុមារនូវក្បួនច្បាប់ឲ្យចេះរស់នៅជាមួយគ្នា និងជួយដល់ការចូលចុះក្នុងសង្គម : គោរពអ្នកដទៃ គោរពសម្ភារ សហការគ្នា ចែករំលែក មិនយកសម្ភារជាប្រយោជន៍ផ្ទាល់ខ្លួន រង់ចាំវេនរបស់ខ្លួន។ ល្បែងនាំកុមារ ឲ្យស្គាល់អ្នកដទៃគេបង្ហាញអារម្មណ៍និងជៀសផុតជម្លោះរបស់គេដោយចចារ និងប្តូរយោបល់។ តាមរយៈល្បែងកុមាររៀន ស្គាល់អ្នកដទៃហើយទុកចិត្តព្រោះថាគេពិតជា ត្រូវការដៃគូលេង។



# ការអភិវឌ្ឍក្ដីស្រលាញ់ និងសង្គម (ត)

- ការចូលសាលាមត្តេយ្យជាកត្តានៃការភ័យបារម្ភខ្លាំង សម្រាប់កុមារមួយចំនួន : អវត្តមានគ្រួសារ ជាចង្វាក់មួយដែលនាំឲ្យកុមារខ្លាច ។ល។
- ល្បែង អាចឲ្យកុមារលេងពីស្ថានភាពអតីតកាល ឬការងារប្រចាំថ្ងៃរបស់គេដែលគេបានរស់នៅមិនល្អ ដូចជាការពិនិត្យរបស់គ្រូពេទ្យ ការប្រឈមនឹងបងប្អូនប្រុសស្រីរបស់គេ នៅពេលលេងស្ថានភាពនោះឡើងវិញ កុមារបំបាត់ទុក្ខសោកនៃស្ថានភាពនោះ និងអាចរៀនបញ្ចៀសភាពធុញថប់ និងភ័យខ្លាចរបស់គេ។ តាមរបៀបទូទៅ កុមារនឹងបង្កើតចំណងទាក់ទងវិជ្ជមាននៅសាលាមត្តេយ្យ ឬនៅក្នុងក្រុមកុមារ ឬជាមួយអ្នកផ្សេង ដោយសារល្បែង ដោយផ្សារភ្ជាប់ជាមួយទីកន្លែង និងមនុស្សប្រកបដោយភាពរីករាយពេញចិត្ត និងមានអារម្មណ៍ល្អ ក្នុងពេលម៉ោងលេង។



# ការអភិវឌ្ឍក្តីស្រលាញ់ និងសង្គម (ត)

- នៅវ័យនេះ កុមារអភិវឌ្ឍទំនុកចិត្តលើខ្លួនឯង។ បើគេគ្មាន ទំនុកចិត្តលើខ្លួនឯង គេមិនអាចក្លាយទៅជាមនុស្សធំដែល មានស្វ័យភាព និងរីកដុះដាលបានទេ។

- នៅពេលដែលអ្នកដឹកនាំសកម្មភាពទុកឲ្យកុមារលេងដោយខ្លួនឯង គឺបង្កឱកាសឱ្យកុមារកសាងទំនុកចិត្តរបស់ខ្លួន។ អ្នកដឹកនាំសកម្មភាព បង្ហាញយ៉ាងល្អិតល្អន់ទៅកុមារ ដែលធ្វើឲ្យពួកគេមានទំនុកចិត្តក្នុងសមត្ថភាពសម្រេចផលល្អដោយខ្លួនឯង និងរុករកតាមរបៀបកសាង។ កាយវិការនេះមានតម្លៃណាស់សម្រាប់ កុមារ និងអាចអភិវឌ្ឍទំនុកចិត្តរបស់គេ។

- ការត្រាប់តាមមនុស្សធំចាប់ផ្តើមយ៉ាងឆាប់រហ័ស។ កុមារចង់ក្លាយជាមនុស្សធំ ម្ចាស់ការខ្លួនឯង និងជាអ្នកសម្រេចចិត្តដូចមនុស្សធំ។គឺដោយការកំណត់អត្តសញ្ញាណដោយខ្លួនឯង និងដោយសម្តែងឡើងវិញនូវតួនាទីមនុស្សធំ ដែលកុមារត្រូវការប្រមូលយកច្បាប់សង្គមនិង វប្បធម៌របស់សង្គម ដែលក្នុងនោះកុមារបានរីកចម្រើនឡើង។

- ល្បែងរៀបចំឆាក និងល្បែងដើរតួ ជាចន្លោះវេលានៃការរាវរក និងការធ្វើពិសោធន៍ ត្រូវចាប់ផ្តើមដោយអ្នកដែលនៅជុំវិញកុមារផ្ទាល់ (ប៉ា ម៉ាក់ កូនង៉ា...) សង្គម (អ្នកលក់ អ្នកគ្រូ អ្នកនេសាទ...) កុមាររាវរកការកំណត់អត្តសញ្ញាណសង្គមផ្សេងៗ។



# ការអភិវឌ្ឍផ្នែកបញ្ញា

## ការអភិវឌ្ឍ ចន្លោះ ៣ ទៅ ៦ឆ្នាំ ក្នុងវិស័យនេះ

- កុមារអាយុ ចន្លោះពី ៣ ទៅ ៦ឆ្នាំ មានការឆ្ងល់ ចង់ដឹង ពីធម្មជាតិច្រើន។កុមារចោទសួរជារឿយៗនូវសំណួរដែលផ្ដើមឡើងដោយ « ហេតុអ្វី ? » មិនថាចំពោះរឿងអ្វីក៏ដោយ។
- ក្នុងវ័យនេះ កុមារមានប្រាជ្ញាដឹងដោយខ្លួនឯងជាញឹកញាប់ វាចាប់ផ្តើមធ្វើការពិចារណា រកហេតុផលពន្យល់បកស្រាយបែបងាយៗមួយចំនួន នៅអាយុ ៤ឆ្នាំ តែប៉ុណ្ណោះ។ កុមារមានការរីកចម្រើនខ្លាំងខាងភាសាក្នុងពេលនោះ កុមារមានវាក្យស័ព្ទចម្រើនលូតលាស់ វានឹងមានលទ្ធភាពយល់ពីពិភពខាងក្រៅ។

## ផលប្រយោជន៍របស់ល្បែង

- ល្បែងធ្វើឲ្យចម្ងល់របស់កុមារមានសន្ទុះកាន់តែខ្លាំង និងអភិវឌ្ឍវិញ្ញាណ ព្រមទាំងគំនិតផ្តួចផ្តើមក្នុងការរាវរក ការធ្វើពិសោធន៍ ការលូតលាស់ភាពម្ចាស់ការ និងសមត្ថភាពរៀនដោយខ្លួនឯង។
- ល្បែងបង្កើតស្ថានភាពជាច្រើនក្នុងការប្រាស្រ័យទាក់ទង រវាងកុមារទាំងឡាយ និងពង្រឹងការលូតលាស់ខាងភាសា។



# ការអភិវឌ្ឍផ្នែកបញ្ញា (ត)

| | |
|---|---|
| ការស្រមើស្រមៃ និងការច្នៃប្រឌិតជាឧបករណ៍សំខាន់ក្នុងការធ្វើឲ្យស្វ័យភាពរបស់កុមារ កាន់តែធំធេង។ | ល្បែងសេរី បណ្ដុះការស្រមើស្រមៃ និងការច្នៃប្រឌិត។ |
| គំនិតប្រឌិតរបស់កុមារសម្បូរណាស់វាបង្កើតថ្មីនូវរឿងទាំឡាយ វាបង្កើតតួអង្គ វាផ្ដល់ជីវិតដល់វត្ថុ ប៉ុន្តែការញែកពីគ្នា រវាងគំនិតច្នៃប្រឌិតនិងការពិតនៅស្រពិចស្រពិលនៅឡើយ។ | ល្បែងអភិវឌ្ឍភាពញែកពីគ្នារវាងគំនិតរវើរវាយនិងការពិត។ ល្បែងផ្ដល់នូវលទ្ធភាពធ្វើបទពិសោធន៍ផ្សេងគ្នា ដែលអាចឲ្យវាធ្វើសកម្មភាពដោយការសាកល្បង និង ការខុសឆ្គង។ ការគិត ដើរមុនកាយវិការ។ |
| ចន្លោះ ៣ និង ៥ឆ្នាំ កុមាររីកចម្រើនខាងការរៀបចំគំនិត បញ្ញា។<br><br>កុមារត្រៀមខ្លួនចូលសាលាបឋមសិក្សា។ | ល្បែងបណ្ដុះការយកចិត្តទុកដាក់ និងការចងចាំ ។ ល្បែងផ្ដល់ឱកាសឲ្យហាត់រៀនក្នុងស្ថានភាព ដែលបានប្រព្រឹត្តនៅពេលផ្សេងគ្នា ហើយដែលអាចធ្វើឲ្យកុមារលេងឡើងវិញបាន។ ការបញ្ជ្រាបឲ្យយល់ពីការប្រើប្រាស់ល្បែង ដើម្បីបញ្ជ្រាបឲ្យយល់នូវសញ្ញាណសិក្សាមួយចំនួន ក៏ដូចជាអាចជួយកុមារដែលត្រូវរាំងស្ទះក្នុងការរៀនសូត្រមួយចំនួនឲ្យផុតពីការលំបាករបស់ពួកគេ។ |



# តើល្បែងសេរីផ្តល់នូវអត្ថប្រយោជន៍ដូចម្តេចខ្លះ?

## ផលប្រយោជន៍ដោយឡែកនៃល្បែងសេរី

- ជាដំបូង ល្បែងសេរី អភិវឌ្ឍ**ជាពិសេស ទំនុកចិត្ត និងស្វ័យភាពរបស់កុមារ។** នៅពេលដែលអ្នកដឹកនាំសកម្មភាព ទុកឲ្យកុមារជ្រើសរើសល្បែងដោយសេរីទៅតាមចំណូលចិត្តរបស់គេ ល្បែងទាំងអស់ពន្លឿនដំណើរការសកម្មរបស់កុមារ ផ្តល់តម្លៃ និងលើកទឹកចិត្តនូវគំនិតផ្តួចផ្តើមរបស់គេ។ កុមារដែលមានអារម្មណ៍ថាត្រូវបានអនុញ្ញាត ឱ្យលេងតាមចំណង់ និងរាវរកដោយសេរី ឃើញថាមានសមត្ថភាពធ្វើបានសម្រេចនូវសកម្មភាពទាំងឡាយដោយខ្លួនឯង ថែមទាំងមានទំនុកចិត្តលើខ្លួនឯង។  តាមរូបមន្តរបស់ បិត្តឹឡាំង(Bettelheim) : «**សារៈសំខាន់ធំបំផុតរបស់ល្បែង ជាភាពរីករាយពេញចិត្តភ្លាមៗដែលកុមារទាញយកមក ហើយបន្ទាយដោយភាពរីករាយនឹងរស់រវើក**»



## ផលប្រយោជន៍ដោយឡែកនៃល្បែងសេរី (ត)

- ជាបន្តមកទៀត ល្បែងសេរី ផ្តោតលើគំនិតដែលតាមធម្មជាតិកុមារត្រូវទាក់ទាញអារម្មណ៍ ចំពោះល្បែងដែល**ឆ្លើយតបនឹងតម្រូវការបញ្ហា និងអារម្មណ៍។** ក្នុងក្របខ័ណ្ឌនៃពេលលេងល្បែងសេរី កុមារនឹងសំដៅទៅល្បែងណាដែលទាក់ទងនឹងតម្រូវការរបស់គេ ហើយជួយផ្គត់ផ្គង់ដល់ការលូតលាស់របស់គេ។ កុមារនឹងជៀសវាង ល្បែងណាដែលងាយពេក ឬពិបាកពេកសម្រាប់គេ ហើយគេត្រូវទាក់ទាញដោយល្បែងដែលបង្ហាញក្មេងតូចៗ នូវកម្រិតនៃការលំបាកដែលអាចធ្វើបានសម្រាប់គេ ឬដែលទាក់ទងនឹងការបំពេញនៃតម្រូវការផ្នែកអារម្មណ៍។ ក្នុងពេលលេងល្បែងសេរីកុមារម្នាក់ៗកំពុងតែធ្វើការពីសមត្ថភាពដែលវាត្រូវការអភិវឌ្ឍ ឬការ លំបាកដែលគេត្រូវការជំនះ ហើយកុមារម្នាក់ៗអាចឈានទៅមុខតាមសង្វាក់ផ្ទាល់ខ្លួនរបស់គេក្នុងការ អភិវឌ្ឍផ្សេងៗ។



## ផលប្រយោជន៍ដោយឡែកនៃល្បែងសេរី (ត)

- នៅទីបញ្ចប់ ល្បែងសេរីផ្តល់ឱកាសឲ្យអ្នកដឹកនាំសកម្មភាព មើលឃើញកាន់តែច្បាស់ពីកុមារទាំងឡាយ និង**តាមដានការអភិវឌ្ឍជាបុគ្គលរបស់ពួកគេ។** ដូច្នេះដោយសារល្បែងសេរី អ្នកដឹកនាំសកម្មភាពស្ថិត ក្នុងស្ថានភាព សង្កេតដោយយកចិត្តទុកដាក់ គេអាចកំណត់កម្រិតនៃការអភិវឌ្ឍរបស់កុមារ តម្រូវការរបស់គេ  ចំណង់ ឬក្តីប្រាថ្នា និងប្រើប្រាស់ការសង្កេតទាំងនោះឡើងវិញដើម្បីនាំកុមារក្នុងថ្នាក់បានកាន់តែល្អ ដោយចេញពីអ្វីដែលពួកគេ ចូលចិត្ត និងត្រូវការអភិវឌ្ឍ។ អ្នកដឹកនាំសកម្មភាពអាចកំណត់ការឈឺចាប់ផ្លូវចិត្ត និងផ្លូវកាយដែលគេត្រូវទៅនិយាយប្រាប់ឪពុកម្តាយ ទៅអាណាព្យាបាលកុមារដូចគ្នា ប្រសិនបើការលំបាករបៀបនេះកើតឡើងដដែលៗ។



# I. អ្វីទៅជាល្បែង និង ល្បែងសេរី?

## អ្វីទៅជាល្បែង?

យើងចាត់ទុកល្បែង ជាឥរិយាបទមួយ ដែលប្រែប្រួលតាមការចូលចិត្តនៅពេលរីករាយ និងទទួលលទ្ធផលភ្លាមៗ។



# អ្វីទៅជាល្បែង និង ល្បែងសេរី? (ត)

## អ្វីទៅជាល្បែងសេរី?

មានធាតុគន្លឹះ៤ កំណត់លក្ខណៈល្បែងសេរីៈ

១. ធានាសេរីភាព៤ ដល់កុមារ :

- ការជ្រើសរើសថាលេង ឬ មិនលេង
- ការជ្រើសរើសល្បែង
- ការជ្រើសរើសរបៀបលេង
- ការជ្រើសរើសថាលេងម្នាក់ឯង ឬ លេងគ្នាច្រើន

២. វត្តមានមនុស្សពេញវ័យ ដើម្បីធានាលក្ខខណ្ឌដ៏ល្អមួយសម្រាប់កុមារទាំងអស់។

៣. រៀបចំទីកន្លែង និងប្រដាប់លេងតាមប្រភេទទាំង៤របស់ល្បែងៈ លំហាត់ ត្រាប់តាម ឬនិមិត្តរូប ផ្គុំ ឬសាងសង់ និងល្បែងមានក្បួន។

៤. ការរៀបចំ ការជ្រើសរើស ដែលប្រែប្រួលប្រដាប់លេងច្រើន ប្រហែល២ល្បែង ក្នុងកុមារម្នាក់។



# អ្វីទៅជាល្បែង និង ល្បែងសេរី? (ត)

## ល្បែងសេរីមិនមែនជា:

- ល្បែងដឹកនាំ ឬពាក់កណ្ដាលដឹកនាំ

ឈុតរបស់ល្បែងដឹកនាំ ត្រូវត្រៀមរៀបចំដោយអ្នកដឹកនាំសកម្មភាព គាត់ជ្រើសរើសល្បែង និងប្រាប់ឲ្យដឹងជាមុននូវដំណើរប្រព្រឹត្តរបស់ល្បែងនោះ។ ផ្ទុយទៅវិញ ក្នុងល្បែងសេរី កុមារជ្រើសរើសល្បែងខ្លួនឯង ហើយអ្នកដឹកនាំសកម្មភាព ទុកភារកិច្ចដឹកនាំល្បែងអោយកុមារ។



# អ្វីទៅជាល្បែង និង ល្បែងសេរី? (ត)

- ពេលចេញលេងនៅសាលា ឬល្បែងក្នុងទីធ្លាសម្រាប់កុមារ

ពេលចេញលេង គឺជាពេលសម្រាកសម្រាប់កុមារ នៅពេលនោះពួកគេលេងដោយសេរី ជាមួយមិត្តភក្តិ តាមតែពួកគេចង់លេង។ ពេលនេះហាក់ដូចជាពេល សិក្សាល្បែងសេរី ជាងល្បែងដឹកនាំ ឬគរុកោសល្យ ប៉ុន្តែ មិនមានការដាក់រៀបចំប្រដាប់លេងជាច្រើននោះទេ។

ល្បែងសេរីស្ថិតក្នុងសកម្មភាពដឹកនាំ និងសកម្មភាព បណ្តោយអោយធ្វើ។



**សំនួរ៖** ចូរស្រង់ឈ្មោះល្បែងដែលអ្នកធ្លាប់ស្គាល់ និង ធ្លាប់លេងតាំងពីនៅកុមារភាព ព្រមទាំងធ្វើចំណាត់ថ្នាក់ល្បែងទាំងនោះទៅតាមប្រភេទនៃល្បែងផង?



# ការចាត់ថ្នាក់ ESAR

## ការចាត់ថ្នាក់ ESAR

ការចាត់ថ្នាក់នេះ ផ្អែកលើការងាររបស់លោក Jean Piaget ដែលជាចិត្តវិទូម្នាក់ក្នុងចំណោមចិត្តវិទូដំបូងគេ ដែលត្រូវបានដេញដោលសួរអំពីផលប្រយោជន៍ផ្សេងៗ របស់ល្បែងសម្រាប់កុមារ។



# ការចាត់ថ្នាក់ ESAR

## ហេតុអ្វីបានជាត្រូវចាត់ថ្នាក់ល្បែងលេង?

ការចាត់ថ្នាក់ល្បែង មានហេតុផលបី :

1. យល់ពីសក្តានុពលលេងរបស់ល្បែង
2. រ៉ាប់រងភាពផ្សេងៗគ្នារបស់ល្បែង
3. ការរៀបចំទីកន្លែងល្បែងដែលស៊ីសង្វាក់គ្នា។

### បង្កាភាពផ្សេងៗគ្នានៃល្បែង:

ការសិក្សាល្បែង អាចធានារ៉ាប់រងប្រភេទប្លែកៗគ្នារបស់វា ដែលអាចអោយមានសេរីភាពជ្រើសរើសកាន់តែច្រើន ក្នុងចំណោមល្បែងនានានៅពេលលេង។



# ការចាត់ថ្នាក់ ESAR (ឥ)

## ការរៀបចំទីកន្លែង:

មានហេតុផលច្រើនបង្ហាញពីការរៀបចំទីកន្លែង ទៅតាមប្រភេទទាំង៤នៃល្បែង:

- ផ្តល់ឱកាសឲ្យកុមារម្នាក់ៗ ងាយស្រួលក្នុងការចូលលេងល្បែង
- ផ្តល់ការសម្គាល់ដល់កុមារទាំងឡាយ។ ការយកចិត្តទុកដាក់របស់កុមារ អាចសំដៅយ៉ាងលឿនទៅលើល្បែងដែលពួកគេចាប់អារម្មណ៍។
- ការចែកទីកន្លែង គឺថែរក្សាល្បែងរបស់កុមារ និងផ្តល់ឲ្យកុមារលេងយ៉ាងស្ងប់ស្ងៀម។

ឧទាហរណ៍: កុមារផ្តោតអារម្មណ៍លើល្បែងផ្គុំរូប ក្នុងទីកន្លែងផ្តុំជៀសវាងការផ្តាច់គម្រោងសាច់រឿងប្រឌិតរបស់កុមារនៅកន្លែងត្រាប់តាម។



# ការចាត់ថ្នាក់ ESAR (ត)

ការចែកថ្នាក់នេះ ញែកល្បែងឲ្យដាច់ជា៤ក្រុម ទៅតាម ដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារដែលនៅពេលនោះកុមារ ទាំងឡាយចាប់ផ្តើមចាប់អារម្មណ៍នឹងប្រភេទនៃល្បែង។ ក្នុង ប្រព័ន្ធ ESAR ការចាត់ថ្នាក់ជា៤ក្រុមនេះ នាំមកនូវការវិភាគល្បែង ដោយប្រៀបធៀបនឹងសមត្ថភាព៤ ដែលល្បែងទទូចចង់បាន:

1. ខាងប្រាជ្ញា ឬ ការស្គាល់
2. ខាងអាការៈក្នុងខ្លួន ឬចលករ
3. ខាងសង្គម ភាសា
4. ខាងក្តីស្រលាញ់។



# ការចាត់ថ្នាក់ ESAR (ត)

គេចាត់ថ្នាក់ល្បែងជា៤ក្រុមទៅតាមដំណាក់កាលទាំង៤: **ដំណាក់កាលវិញ្ញាណចលករ ដំណាក់កាលតំណាង ដំណាក់កាលយល់ដឹងដោយញាណ និងដំណាក់កាលប្រតិបត្តិ។**

ប្រភេទល្បែងទាំង៤ក្រុមមាន:

- ល្បែងលំហាត់ (E : Exercise)
- ល្បែងនិមិត្តរូប ឬ ត្រាប់តាម (S : Symbolic)
- ល្បែងផ្គុំ/សាងសង់ (A : Assembly)
- ល្បែងមានក្បួន (R : Rule)។



# ប្រភេទទាំង៤នៃល្បែងសេរី

## ល្បែងលំហាត់

ល្បែងលំហាត់ គឺជាសកម្មភាពកើតឡើងដដែលៗដោយវិញ្ញាណ ឬចលករ ក្នុងគោលដៅជាក់លាក់ ឬគ្មានគោលដៅបញ្ជាប់ ដើម្បីអោយមានភាពរីករាយនៃលទ្ធផលភ្លាមៗ។

ឧទាហរណ៍: អំពើដដែលរបស់ទារក ឬកុមារតូចលេងជាមួយល្បែងឬដោយគ្មានល្បែងគឺអាចចាត់ទុកថាជាល្បែងលំហាត់។

# ប្រភេទផ្សេងៗនៃល្បែងលំហាត់

## ល្បែងខាងវិញ្ញាណ

លំហាត់ និងសកម្មភាពល្បែង ដែលរួមបញ្ចូលវិញ្ញាណប្រាំ: ល្បែងស្តាប់សូរ ល្បែងសង្កេត ល្បែងប៉ះស្ទាប ល្បែងហិតក្លិន និងភ្លក្សរសជាតិ។

ឧទាហរណ៍: ឧបករណ៍ភ្លេង

ប្រអប់ទិព្វ...





# ប្រភេទផ្សេងៗនៃល្បែងលំហាត់ (ត)

## ល្បែងចលករ

លំហាត់ និងសកម្មភាពល្បែង ដែលរួមបញ្ចូលចលនាកម្រើក ឬផ្លាស់ប្តូរកន្លែងដូចជា ដើរ រត់ លោត តោង វារ ប្រមៀលខ្លួន រុញ ទាញ និងចលនាសកម្មជាក់លាក់ណាមួយ ដូចជា: ឱនបន្ទន់ខ្លួន ពត់ខ្លួន បង្វិលជុំវិញខ្លួនឯង បោះ ដេញចាប់ ។ល។

ឧទាហរណ៍: បាល់ ខ្សែលោត កងបង្វិល...

# ប្រភេទផ្សេងៗនៃល្បែងលំហាត់ (ត)

## ល្បែងលេងដោយដៃចាប់កាន់

លំហាត់និងសកម្មភាពល្បែង ដែលរួមបញ្ចូលចលនាកាន់ ដូចជា ឆក់ច្បាម រិត វាយ សូនរូប ទាញ ឬរុញដោយដៃ ចាក់ចេញឲ្យទទេ ឬចាក់បំពេញៗល។

ឧទាហរណ៍: ល្បែងដេរ/ដោត ល្បែងលេងជាមួយទឹក...







# ប្រភេទផ្សេងៗនៃល្បែងលំហាត់ (ត)

## តើល្បែងលំហាត់ជួយអភិវឌ្ឍអ្វីខ្លះដល់កុមារ?

### សមត្ថភាពដែលអភិវឌ្ឍដោយល្បែងលំហាត់

ល្បែងលំហាត់ នាំមកនូវការ**អភិវឌ្ឍវិញ្ញាណ និងចលករ** ភាពស្រួចស្រាវខាងវិញ្ញាណ ការសម្របសម្រួលផ្នែកវិញ្ញាណនិងកាយវិការ ការសម្របសម្រួលចលនា អភិវឌ្ឍលំនឹង។ល។ វានាំមកនូវការអភិវឌ្ឍបញ្ញាផងដែរ។ល្បែងលំហាត់ដែលចាំបាច់ មានការកាន់វត្ថុ អាចផ្តល់ឱកាសបានដល់**សញ្ញាណនៃទម្ងន់ ទ្រង់ទ្រាយ**ទៀតផង។

# ល្បែងត្រាប់តាម វិនិមិត្តរូប

**ល្បែងត្រាប់តាម** ជាល្បែងដែលក្នុងនោះ វត្ថុមួយអាចត្រូវតំណាងដោយវត្ថុមួយទៀត។ កុមារប្រើដុំឈើធ្វើដូចជាកូនឡាន ឬយន្តហោះមួយ តក្កតាក្លាយជាកុមារតូចម្នាក់ដែលនិយាយ។

ល្បែងនេះមានរូបភាពពីជីវិតពិត (ត្រាប់តាមឆាកជីវិត) ការប្រឌិតព្រឹត្តិការណ៍ថ្មី ប្លែក តាមរយៈតួអង្គពិត ឬប្រឌិតដែលរាល់តួនាទីទាំងអស់ ត្រូវបានគេកំណត់រួចជាស្រេច។

# ប្រភេទផ្សេងៗ នៃល្បែងនិមិត្តរូប

## ល្បែងដើរតួ

ល្បែងធ្វើឲ្យដូច ដែលក្នុងល្បែងនោះ កុមារខ្លួនឯងជាតួអង្គ។ ដោយប្រើសម្លៀកបំពាក់ ការក្លែងខ្លួន មុខត្លុក ឬគ្រឿងបន្ទាប់បន្សំ កុមារគ្រាប់តាមអំពើកាយវិការ សំដី ដែលទាក់ទងនឹងតួអង្គដែលកុមារតំណាង។



ឧទាហរណ៍: ឈុតវេជ្ជបណ្ឌិត
បាយឡុកបាយឡ...



# ប្រភេទផ្សេងៗ នៃល្បែងនិមិត្តរូប (ត)

## ល្បែងតំណាង

ការតំណាងមាន ផលិតគំនូរ គំនូរផាត់ពណ៌ ការផ្គុំ ការសូនរូប ការឆ្លាក់... ក្នុងគោលដៅតំណាងតួអង្គ វត្ថុ ទ្រង់ទ្រាយ ព្រឹត្តិការណ៍ បរិស្ថាន ។ល។

ឧទាហរណ៍ : ម្សៅសម្រាប់សូនរូប ខ្មៅដៃពណ៌...

# ប្រភេទផ្សេងៗ នៃល្បែងនិមិត្តរូប (ត)

## ល្បែងដឹកនាំឈុត/ឆាក

ក្នុងនោះអ្នកលេង ជាអ្នកដឹកនាំរឿងៗ គាត់តំណាងតួអង្គដោយធ្វើឲ្យវត្ថុ ឬរបស់លេងមានចលនា ទៅតាមព្រឹត្តិការណ៍ ស្ថានភាពពិត ឬប្រឌិត។



ឧទាហរណ៍: កូនឡាន តុក្កតា សត្វធ្វើពីឈើ...



# ប្រភេទផ្សេងៗ នៃល្បែងនិមិត្តរូប (ត)

## តើល្បែងនិមិត្តរូបជួយអភិវឌ្ឍន៍អ្វីខ្លះដល់កុមារ?

### សមត្ថភាពអភិវឌ្ឍដោយល្បែងនិមិត្តរូប

ល្បែងនិមិត្តរូប **បណ្ដុះគំនិតស្រមៃ ការប្រឌិត និងភាសា**របស់កុមារ។ កុមារធ្វើការទាក់ទងដោយគ្មានជំនួយពីមនុស្សធំ កុមារអាចបង្កើតការសន្ទនារវាងវត្ថុដែលវាធ្វើឲ្យមានចលនា វាអាចប្តូរជាមួយកុមារដទៃទៀត នៅពេលវាលេងច្រើននាក់ ឬអធិប្បាយអំពើរបស់វាទៅមិត្តភក្តិ។

# ប្រភេទផ្សេងៗ នៃល្បែងនិមិត្តរូប (ត)

## សមត្ថភាពអភិវឌ្ឍដោយល្បែងនិមិត្តរូប (ត)

កុមារមិនគ្រាន់តែត្រាប់តាមការពិតប៉ុណ្ណោះទេ វាបំប្លែងការពិតទៅតាមបំណងរបស់វា។

ល្បែងត្រាប់តាមផ្តល់ឱកាសឲ្យកុមារលេងឡើងវិញនូវស្ថានភាពនៃអតីតកាលរបស់វា សកម្មភាពប្រចាំថ្ងៃរបស់វា ដែលវារស់នៅមិនបានល្អ ដូចជាការជួបគ្រូពេទ្យ ការប្រឈមមុខជាមួយបងប្អូនប្រុសស្រី... ក្នុងពេលលេងស្ថានភាពនោះឡើងវិញ កុមារបង្រួមទំហំព្រឹត្តិការណ៍ និងអាចរៀនឈ្នះលើការភ័យបារម្ភ និងការខ្លាច។



# ល្បែងផ្គុំ ឬ សាងសង់

ល្បែងផ្គុំ មានផ្គុំដាក់បញ្ចូលដំណាប់ ដាក់ត្រួតលើគ្នា ដាក់គរលើគ្នានូវបំណែកទាំងឡាយ ដើម្បីបង្កើតសំណុំវត្ថុមួយជាក់លាក់។



# ល្បែងផ្គុំ ឬ សាងសង់ (ត)

## ប្រភេទផ្សេងៗនៃល្បែងផ្គុំ ឬ សាងសង់

### ល្បែងសាងសង់

ល្បែងផ្គុំដែលអាចឲ្យធ្វើបាននូវសំណង់មួយមាន**បីវិមាត្រ** ពីធាតុដាច់ៗ ដោយប្រើបច្ចេកទេសផ្សេងៗនៃការដាក់ត្រួតលើគ្នា ការមួលវីស ការភ្ជាប់ប៊ូឡុង ការស្លង់ភ្ជាប់គ្នា ការបិទការ។ល។

ឧទាហរណ៍: ប្រអប់ប្រដាប់ប្រដាជាងកាផ្លា ...





# ល្បែងផ្គុំ ឬ សាងសង់ (ត)

## ល្បែងតម្រៀប

ល្បែងផ្គុំមាន **ពីរវិមាត្រ**ដែលធ្វើបានដោយ ការខាំជាប់គ្នា(ការបន្សុីគ្នា) ការសឺកដំណាប់ ការដាក់ផ្នែកទាំងឡាយបន្ទាប់ៗទន្ទឹមគ្នា ដោតចេស ការប៉ាក់ដោយម៉ាស៊ីន ការត្បាញ។ល។

ឧទាហរណ៍ : ល្បែងផ្គុំរូប (puzzles )។ល។



# តើល្បែងផ្គុំ/សាងសង់ជួយអភិវឌ្ឍអ្វីខ្លះដល់កុមារ?



# ល្បែងផ្គុំ ឬ សាងសង់ (ត)

## សមត្ថភាពអភិវឌ្ឍ ដោយល្បែងផ្គុំ ឬ សាងសង់

ល្បែងទាំងនេះ ជួយធ្វើឲ្យការសម្របសម្រួលភ្នែក-ដៃបានប្រសើរឡើង ការញែកឲ្យឃើញភាពខុសគ្នានៃទ្រង់ទ្រាយ និងពណ៌ ការតម្រង់ទិសក្នុងលំហ ការចងចាំ ការប្រមូលអារម្មណ៍ និងភាពអំណត់ផងដែរ។ ដូច្នេះ ល្បែងផ្គុំ/សាងសង់លើកកំពស់សមត្ថភាពរបស់កុមារ ឲ្យធ្វើយុទ្ធសាស្ត្រ តាមរបៀបស្វ័យភាព។

លទ្ធផលដែលទទួលបាន គឺពង្រឹងការស្គាល់តម្លៃខ្លួនឯងផងដែរ។



# ល្បែងមានក្បួន

ល្បែងមានក្បួនជាល្បែងដែលមាន ការអប់រំបន្ត និង ក្បួនដែលអ្នកលេង ត្រូវស្គាល់ និងគោរព ដើម្បីបានដល់ គោលបំណងមួយដែលកំណត់។

# ល្បែងមានក្បួន (ត)

## ប្រភេទផ្សេងៗ នៃល្បែងមានក្បួន

### ល្បែងរួមគ្នាជាពួក ឬក្រុម

ល្បែងដែលមាន ការប្រៀបធៀប ដាក់ជិតគ្នា ប្រជុំគ្នា ទៅតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ពីមុន ធាតុពីរ ឬច្រើន ដូចគ្នា ឬផ្សេងគ្នា។

ឧទាហរណ៍ : ល្បែងដូមីណូ ល្បែងចងចាំ ឡូត្តូរូបភាព...





# ល្បែងមានក្បួន (ត)

## ល្បែងវិលជុំ

ល្បែងដែលមានធ្វើការផ្លាស់ទីកន្លែង លើជុំ (វង់មូល) លើផ្លូវត្រូវធ្វើដំណើរ។ ជារឿយៗ ការធ្វើដំណើរ មានក្រឡាពិសេសដែលចង្អុល បង្ហាញលក្ខណៈពិសេសរបស់ល្បែង។

ឧទាហរណ៍ : ល្បែងសត្វក្ងាន ...

# ល្បែងមានក្បួន (ត)

## ល្បែងតម្រង់ទី និងល្បែងកីឡា

ល្បែងដែលមាន ប្រើប្រាស់រាងកាយ ក្នុងគោលដៅមួយដែលកំណត់បន្ទាប់ពីបានវិភាគស្ថានភាព។

ឧទាហរណ៍ : ល្បែងបោះប៊ូល (គីយ) «Quilles»





# ល្បែងមានក្បួន (ត)

## ល្បែងយុទ្ធសាស្ត្រ

ល្បែងដែលមានការវិភាគស្ថានភាពមួយ ឬរូបរាងខាងក្រៅមុននឹងធ្វើ ជ្រើសរើសល្បិចមួយ ហើយរៀបចំឲ្យមានផែនការសកម្មភាព។

ឧទាហរណ៍ : ល្បែងមេទា និងកូនទា ...



# ល្បែងមានក្បួន (ត)

## ល្បែងចៃដន្យ ឬល្បែងភ្នាល់

ល្បែងដែលមានការធ្វើការសម្រេចចិត្ត និងធ្វើសកម្មភាព ដោយផ្អែកលើមូលដ្ឋាននៃភាពចៃដន្យ មិនអាចកំណត់លទ្ធផលជាមុនបាន។

ឧទាហរណ៍ : ល្បែងប្រណាំង តុបតែងលម្អសត្វពស់...



# តើល្បែងមានក្បួនជួយអភិវឌ្ឍអ្វីខ្លះដល់កុមារ?



# ល្បែងមានក្បួន (ត)

## សមត្ថភាពដែលអភិវឌ្ឍដោយល្បែងមានក្បួន

ល្បែងមានក្បួនជួយដល់ការអភិវឌ្ឍខាងភាសា ការយកចិត្តទុកដាក់ ការចងចាំ ការពិចារណា និងការគិត។ តាមរយៈសកម្មភាពល្បែងនេះ មានកុមារឈ្នះនិងចាញ់ កុមារលេងម្នាក់ម្តងតាមវេន គោរពក្បួន និងអ្នកលេងផ្សេងទៀត។

កុមាររៀនត្រួតពិនិត្យភាពជាអ្នកឈ្លានពានរបស់ពួកគេដោយ**ក្លាយទៅជាម្ចាស់ការ គោរពច្បាប់ និងអ្នកដទៃ បង្កើនទំនុកចិត្តលើខ្លួនឯង និងអ្នកដទៃ។**



# II. តើត្រូវអនុវត្តម៉ោងសិក្សាល្បែងសេរីបែបណា?

# ❖ តើត្រៀមរៀបចំពេលសិក្សាបែបណា?

➢ ត្រៀមរៀបចំលក្ខខណ្ឌនៃពេលសិក្សា

នៅពេលត្រៀមពេលសិក្សាល្បែងសេរីមួយ មានលក្ខខណ្ឌមួយចំនួនត្រូវផ្តាំផ្ញើ។

បន្ទាប់ពីការពិសោធរបស់ផ្លូវដើរសម្រាប់កុមារ លក្ខខណ្ឌប្រសើរសម្រាប់ពេលសិក្សាល្បែងសេរីមួយមាន:

- ពេលម៉ោងទៀងទាត់: យ៉ាងតិច1 ទៅ 2ពេលក្នុងមួយសប្តាហ៍
- ទីកន្លែង 2x2m សម្រាប់កុមារម្នាក់
- វត្តមានអ្នកដឹកនាំសកម្មភាពម្នាក់ សម្រាប់កុមារ 12នាក់
- មានប្រដាប់លេង2 ឬល្បែង2 សម្រាប់កុមារម្នាក់។



# តើត្រៀមរៀបចំពេលសិក្សាបែបណា? (ត)

រយៈពេលនៃពេលសិក្សាមួយ ត្រូវគ្រោងទុក1ម៉ោង ទៅ1ម៉ោងកន្លះ ក្នុងពេលលេង:

- 10 – 15 នាទី ដើម្បីត្រៀមរៀបចំពេលសិក្សា
- 45 – 60 នាទី ដើម្បីលេង
- 10 – 15 នាទី ដើម្បីរៀបទុកដាក់ប្រដាប់ប្រដាលេង

ការផ្លាស់ប្តូរ (អ្នកដឹកនាំសកម្មភាព កន្លែងសកម្មភាព ពេលម៉ោង) ត្រូវជៀសវាងឲ្យបានជាអតិបរមា ព្រោះការផ្លាស់ប្តូរនេះបណ្តាលឲ្យមានការភ័យ ព្រួយបារម្ភ សម្រាប់កុមារតូចៗ។



# តើត្រៀមរៀបចំពេលសិក្សាបែបណា?(ត)

- ## ជ្រើសរើសល្បែង

ការជ្រើសរើសល្បែង ត្រូវសម្រិតសម្រាំងឲ្យបានល្អត្រូវមានចំនួនល្បែងស្មើគ្នាក្នុងកន្លែងនីមួយៗ។ពេលនេះនៅសាលាមត្តេយ្យចំនួនល្បែងក្នុងកន្លែងល្បែងនិមិត្តរូប/ត្រាប់តាម អាចសម្បូរជាងគេពីព្រោះជារឿយៗ កុមារតូចៗបង្ហាញការជក់ចិត្តច្រើនជាងគេចំពោះល្បែងទាំងនេះ។ កុមារអាយុ ពី៣ ទៅ៦ឆ្នាំលេងល្បែងរៀបចំឈុត-ឆាក និងល្បែងដើរតួជាច្រើន។គេចាប់យកបានពិភពដែលនៅជុំវិញគេ និងត្រៀមខ្លួនសម្រាប់អនាគតរបស់ពួកគេ។ ផ្ទុយទៅវិញក្នុងកន្លែងល្បែងមានក្បួន ចំនួនវត្ថុ និងរបស់លេងអាចត្រូវកំណត់ពីព្រោះជាទូទៅកុមារមិនសូវចូលចិត្តទេ។



# តើត្រៀមរៀបចំពេលសិក្សាបែបណា? (ត)

នៅពេលជ្រើសរើសល្បែង អ្នកដឹកនាំសកម្មភាពត្រូវគិតគូរដល់ហានិភ័យដែលកើតមានដោយប្រដាប់ប្រដាលេងមួយចំនួន។ ត្រូវប្រុងប្រយ័ត្នដល់ផ្នែកដែលតូចៗពេក ដល់វត្ថុដែលអាចមុត ឬធ្វើឲ្យរបួស និងផលិតផលពុលដូចជា ថ្នាំលាបមួយចំនួន ជ័រការ ឬថ្នាំពណ៌។



# តើត្រៀមរៀបចំពេលសិក្សាបែបណា? (ត)



# តើត្រៀមរៀបចំពេលសិក្សាបែបណា? (ត)

- **ត្រៀមរៀបចំស្តុក**

ប្រព័ន្ធនៃស្តុកមួយល្អ សម្រួលការរៀបទុកដាក់ប្រដាប់លេងបានរហ័ស និងជៀសវាងការបាត់បង់បំណែករបស់ល្បែងៗ ជាដំបូង គួរតែប្រើកេស (ហិប) មួយជាពិសេសសម្រាប់ល្បែងមួយប្រភេទ ដោយមានពណ៌ផ្សេងៗគ្នាទៅតាមកេសៗ យើងបានជ្រើសរើស: **ពណ៌លឿង សម្រាប់ល្បែងលំហាត់ ពណ៌ខៀវ សម្រាប់ល្បែងនិមិត្តរូប/ត្រាប់តាម ពណ៌បៃតងសម្រាប់ ល្បែងផ្គុំ/សាងសង់ និងពណ៌ក្រហមសម្រាប់ល្បែងមានក្បួន** ។

# តើត្រៀមរៀបចំពេលសិក្សាបែបណា?(ត)

ខាងក្នុងហិបទាំងនោះ ជាស្តុកដែលមានលក្ខណៈពិសេស សម្រាប់ល្បែងនីមួយៗ។ ការប្រើប្រាស់ប្រអប់ផ្លាស្ទិក មានពណ៌ថ្លា ងាយស្រួលនឹងដៅចំណាំល្បែងខាងក្នុងយ៉ាងរហ័ស ហើយងាយស្រួលនឹងដាក់ត្រួតលើគ្នា។





# តើត្រៀមរៀបចំពេលសិក្សាបែបណា?(ត)



ស្លាកពណ៌ភ្លឺដោយមានចំនួនដុំលើប្រអប់នីមួយៗ អាចឲ្យផ្ទៀងផ្ទាត់ បានយ៉ាងរហ័ស បើដុំណាមួយនៃសម្ភារៈ ត្រូវបានច្រឡំដៃ មិនដឹងទុកនៅឯណា។បញ្ជីសារពើភ័ណ្ឌពេញលេញមួយរបស់ល្បែងទាំងអស់ត្រូវរៀបចំ ដែលមានបញ្ជាក់ចំនួនដុំបំណែកតាមល្បែងនីមួយៗ។ បញ្ជីសារពើភ័ណ្ឌនេះត្រូវនៅខាងក្នុងហិបដើម្បីផ្ទៀងផ្ទាត់វត្ថុមាន និងស្ថានភាពប្រដាប់ប្រដាលេង នៅពេលរៀបចំទុកដាក់។

# តើត្រៀមរៀបចំពេលសិក្សាបែបណា?(ត)

- ធ្វើឲ្យមានភាពប៉ិនប្រសប់ជាមួយល្បែង



មុននឹងបង្ហាញល្បែងដល់កុមារ ជាសំខាន់អ្នកដឹកនាំសកម្មភាពត្រូវតែស្ទាត់ខ្លួនគាត់ជាមួយល្បែងនីមួយៗ។ ការធ្វើឲ្យធ្លាប់ និងស្ទាត់នេះ ចាំបាច់ត្រូវការមុនអ្វីៗទាំងអស់សម្រាប់ល្បែងមានក្បួន និងសូមយកពេលលេងល្បែងមុននឹងពន្យល់ទៅកុមារ។ ដូចយើងនិយាយជារឿយៗអំពីល្បែង "យើងរៀនលេងដោយលេង... ដោយលេងច្រើនដង!"



# ❖ តើគ្រូធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?

## 1. តួនាទីរបស់អ្នកដឹកនាំសកម្មភាពនៅពេលចាប់ផ្តើម

➢ **រៀបចំទីកន្លែងល្បែង:** កន្លែងល្បែង អាចត្រូវចែកតាមគំនូសបំព្រួញខាងក្រោម៖






# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

ខ្សែបូរពណ៌ (ពណ៌លឿង ពណ៌ខៀវ ពណ៌បៃតង ឬពណ៌ក្រហម)





# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

ដើម្បីធ្វើឲ្យកាន់តែច្បាស់ នូវការចែកទីកន្លែងជា៤ គួរតែប្រើជញ្ជាំងខ័ណ្ឌទាបៗ ដែលអាចតុបតែង និងផាត់ពណ៌បាន ឬអំពីក្រណាត់បូរដែលមានពណ៌ស្រាប់។ ជញ្ជាំងខ័ណ្ឌទាំងនេះមានមុខងារខុសៗគ្នា នៅក្នុងកន្លែងផ្សេងៗគ្នា។



# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

ប្រសិនបើបន្ទប់ ជាកន្លែងរបស់ល្បែងជាអចិន្ត្រៃយ៍ ទូមានថ្នាក់អាចចែកទីកន្លែង និងអាចឲ្យរៀបចំទុកដាក់ប្រដាប់លេងបានយ៉ាងងាយ។ ជញ្ជាំងអាចលាបថ្នាំពណ៌ផ្សេងៗ ដើម្បីផ្តល់នូវការចំណាំទីកន្លែងដល់កុមារ។

ដូចស្តែងឡើងលើគំនូសបំព្រួញ ត្រូវមានចន្លោះផ្លូវចូលកន្លែងនីមួយៗ។ ដើម្បីកាត់បន្ថយហានិភ័យ ប៉ះពាល់ល្បែងរបស់អ្នកផ្សេង ត្រូវលើកទឹកចិត្តកុមារឲ្យប្រើប្រាស់ច្រកចូល និងមិនឆ្លងពីលើរបាំង។

# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

- **រៀបចំដាក់ប្រដាប់លេង**

នៅពេលរៀបចំដាក់ប្រដាប់លេងមុនពេលលេង អាច**សម្រួលការចូលលេងល្បែងរបស់កុមារ។** ជាដំបូង សំខាន់គឺការរៀបចំដាក់ល្បែង **ផ្តល់ចំណាប់ឲ្យកុមារចង់លេង។** ក្នុងកន្លែងល្បែងនិមិត្តរូប អ្នកដឹកនាំសកម្មភាពត្រូវតែដាក់ឲ្យមានឆាកតុក្កតា ដើម្បីសម្រួលការចូលក្នុងល្បែងរបស់កុមារ និងជំរុញឲ្យកុមារមានគំនិតច្នៃប្រឌិត។ ចំពោះកន្លែងផ្គុំ/សាងសង់សម្រាប់ដុំឥដ្ឋ ត្រូវរៀបចំដាក់ដោយផ្តើមដំបូងនូវសំណង់តូចៗ កំពស់ ពីរ-បីឥដ្ឋ។



# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

- **រៀបចំដាក់ប្រដាប់លេង(ត)**

ប្រអប់ផ្លាស្ទិក ដែលប្រើដើម្បីដាក់ប្រដាប់លេង មិនត្រូវទុកចោលក្នុងទីកន្លែងល្បែងក្នុងពេលម៉ោងលេងទេ។ សំខាន់ណាស់ ត្រូវទុកដាក់ឡើងវិញ ក្នុងកេស មុននឹងចាប់ផ្តើមពេលម៉ោងលេង។ ចន្លោះពេលម៉ោងលេងទីពីរ អ្នកដឹកនាំសកម្មភាព រៀបចំទីកន្លែង ដើម្បីធ្វើឲ្យស្អាត និងទាក់ទាញអារម្មណ៍ សាជាថ្មី។

# តើគ្រូធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

## 2. តួនាទីក្នុងពេលម៉ោងលេងល្បែង

- **ហៅឲ្យចូលលេង**

នៅពេលចាប់ផ្តើមលេង អ្នកដឹកនាំសកម្មភាពសុំឲ្យកុមារគោរពការណែនាំខ្លះរបស់ល្បែងសេរីៈ

- ថែរក្សាល្បែង
- គោរពអ្នកដទៃ និងរបៀបលេង
- ចូលរួមក្នុងការរៀបចំទុកដាក់ល្បែងនៅពេលចប់ម៉ោង។



# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

- លេងជាមួយ

នៅពេលកុមារទទួចសុំឲ្យអ្នកដឹកនាំសកម្មភាពចូលរួមក្នុងល្បែងរបស់វា អ្នកដឹកនាំសកម្មភាពនោះពិតជាអាចឆ្លើយតបដោយរីករាយ និងអនុគ្រោះ។





# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

- ពន្យល់ក្បួន/ច្បាប់ល្បែង

នៅពេលមានល្បែងថ្មីៗ ត្រូវបានដាក់បញ្ចូលមក អ្នកដឹកនាំសកម្មភាពអាចនាំល្បែងនោះ មកពន្យល់កុមារ។ការជួយគាំទ្រនេះ ចាំបាច់ណាស់ សម្រាប់ល្បែងមានក្បួន។

ពេលនោះ អ្នកដឹកនាំសកម្មភាពអាចលេងជាមួយកុមារមួយភ្លែត ដើម្បីបង្កផលប្រយោជន៍របស់ពួកគេ។ អ្នកដឹកនាំសកម្មភាព ត្រូវតែសាកល្បងបណ្តោយឲ្យកុមារមានភាពម្ចាស់ការលើល្បែង។





# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

- ទុកឲ្យលេង

## - នៅស្ងៀមមិនបញ្ចេញ (វាចា-កាយវិការ)

ក្នុងពេលម៉ោងល្បែងសេរី អ្នកដឹកនាំសកម្មភាពភាគច្រើនស្ថិតក្នុងពេលដកខ្លួនសម្រាក។សំខាន់ត្រូវគោរពរង្វង់ល្បែងរបស់កុមារ ជៀសវាងធ្វើអន្តរាគមន៍ និងកែប្រែដំណើរប្រព្រឹត្តនៃល្បែងរបស់កុមារ ជាពិសេសក្នុងកន្លែងនិមិត្តរូប ក្រៅអំពីសន្តិសុខ មិនមានការបង្គាប់ណាផ្តល់ឲ្យទេ។ត្រូវបណ្តោយទុកឲ្យកុមារធ្វើពិសោធន៍ និងការរកឃើញរបស់វាផ្ទាល់។



# តើគ្រូធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

- **សង្កេតដោយយកចិត្តទុកដាក់**

តួនាទីគន្លឹះរបស់អ្នកដឹកនាំសកម្មភាព គឺសង្កេតពេលម៉ោងកុមារលេង និងការចូលរួមរបស់កុមារ។

ការសង្កេតនេះ ត្រូវយកចិត្តទុកដាក់ដល់គោលបំណងបី៖

# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

- ជាដំបូង ការសង្កេតនេះ អាច**ធានារ៉ាប់រងកុមារ។** ជាញឹកញាប់ណាស់ ជាពិសេសនៅអាយុពី 3 ទៅ6ឆ្នាំ កុមារឃ្លាំមើលការសម្លឹងរបស់មនុស្សធំ ដើម្បីដឹងខ្លួនថាកាន់តែមានទំនុកចិត្ត។ អ្នកដឹកនាំសកម្មភាពត្រូវតំណាង មូលដ្ឋាននៃសេចក្ដីស្រឡាញ់ពិតប្រាកដសម្រាប់កុមារម្នាក់ៗ ដោយបង្ហាញការយកចិត្តទុកដាក់ដល់កុមារ និងដោយលើកទឹកចិត្ត ឬដោយសរសើរកុមារ នៅពេលណាដែលគេធ្វើបានសម្រេចផលល្អ។ សារសំខាន់នៃការជួយគាំទ្រដោយក្ដីស្រឡាញ់នេះ មិនត្រូវធ្វេសប្រហែសឡើយ។

# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

- ការសង្កេតពេលម៉ោងលេងរបស់កុមារ អាចឲ្យកត់ចំណាំផងដែរថា តើចាំបាច់ត្រូវ **បន្ថែមការផ្តល់ល្បែងទៀត ឬទេ។** អាចគិតគូរប្តូរប្រដាប់ប្រដាលេងមួយចំនួន ប្រសិនបើល្បែងងាយពេក ឬពិបាកពេកសម្រាប់កុមារ ឬមិននាំមកនូវសេចក្តីរីករាយពេញចិត្ត ដល់កុមារ ឬបើមិនសូវរឹងមាំ។



# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

❖ នៅទីបញ្ចប់ អ្នកដឹកនាំសកម្មភាព អាចមានឱកាស **កត់ចំណាំកុមារដែលមានការលំបាក ឬមួយមានការឈឺចាប់ផ្លូវចិត្ត**ដូចជា:

- កុមារមិនអាចចូលលេងល្បែងណាមួយ ហើយនៅដាច់ពីគេ
- កុមារអាចលេងដោយកម្រ មិនដែលសោះ វាឆ្លងពីល្បែងមួយទៅល្បែងមួយទៀត វាបង្ហាញការលំបាកក្នុងការប្រមូលអារម្មណ៍
-កុមារបង្ហាញរបៀបលេងមិនមែនជាបែបផែនលេងដដែលៗចម្លែកខុសពីគេ
- កុមារតំណាងស្ថានភាព ដែលខ្លឹមសារត្រូវបារម្ភ ដែលនាំឲ្យនឹកឃើញដល់ការរំលោភ ឬអំពើហឹង្សា។



# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

ក្នុងករណី កុមារម្នាក់ដែលមិនលេង ដែលនៅកៀនតែឯង មិនមានចំណង់ចូលរួម អ្នកដឹកនាំសកម្មភាពត្រូវសាកល្បងស្វែងយល់ ជាអ្នកស្ដាប់កុមារ លើកទឹកចិត្តកុមារឲ្យនិយាយប្រាប់ និងនាំអោយមានទំនាក់ទំនងជាមួយអ្នកឯទៀត។ អ្នកដឹកនាំសកម្មភាព អាចលេងក្បែរ ឬពីមុខកុមារ ដើម្បីបបួលវាឲ្យលេង។

**បង្ខំឲ្យកុមារលេង វាផ្ទុយនឹងល្បែងសេរី។**

# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

- **ធានាសុវត្ថិភាព**

សុវត្ថិភាព ត្រូវបានធានារ៉ាប់រង
ដោយអ្នកដឹកនាំសកម្មភាពក្នុងពេល
ម៉ោងលេងល្បែងសេរី។ ជាការពិត
គោលបំណងនៃពេលម៉ោងល្បែងសេរី
គឺទុកកន្លែងមានសេរីភាពឲ្យកុមារ
ប្រកបដោយក្បួនច្បាប់យ៉ាងតិចតួច។
ជារឿងធម្មតា ទុកឲ្យកុមាររត់ និងធ្វើ
សម្លេងក្ដុងក្ដាំងក្នុងពេលល្បែងសេរី។



# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

យើងសង្ឃឹមបង្កើតបរិយាកាសមួយ "ស្ងប់ស្ងាត់ និងរីករាយ"។ ប៉ុន្តែ នៅពេលអាកប្បកិរិយាកុមារម្នាក់ បង្ហាញហានិភ័យចំពោះអ្នកឯទៀតនោះ អ្នកដឹកនាំសកម្មភាព ត្រូវធ្វើអន្តរាគមន៍ដើម្បីធ្វើឲ្យមានសុវត្ថិភាពដូចដើមវិញ។ ក្នុងពេលអន្តរាគមន៍ អ្នកដឹកនាំសកម្មភាព អាចសាកល្បងពន្យល់ដោយស្ងៀមស្ងាត់ទៅកាន់កុមារ។



# តើគ្រូធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

➤ **ប្រមូលប្រដាប់លេង ដែលរប៉ាត់រប៉ាយដាក់នៅកន្លែងដើមវិញ**

អ្នកដឹកនាំសកម្មភាព ត្រូវសាកល្បងការពាររៀបចំទីកន្លែងជា ៤ ហើយរក្សារបៀបរៀបរយក្នុងល្បែង និងប្រដាប់លេង។



ការថែរក្សាទីកន្លែងល្បែងនេះ ជៀសវាងបាត់សម្ភារ នឹងរក្សាទីកន្លែងទាក់ទាញអារម្មណ៍សម្រាប់កុមារក្នុងពេលម៉ោងលេង។

ឧទាហរណ៍: បើល្បែងមួយចំនួនត្រូវទុកចោលក្នុងកន្លែងផ្សេង អ្នកដឹកនាំសកម្មភាព អាចយកវាដាក់នៅកន្លែងដើមវិញ ឬដាក់រូបតូចៗឲ្យឈរវិញ ឬពាក់រូបឲ្យតក្កតាវិញ។



# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

- **អញ្ជើញឪពុកម្តាយមកមើលពេលម៉ោងលេង**

ជាពិសេស បន្ទាប់ពីបានប្រាប់កុមារ ឪពុកម្តាយត្រូវបានអញ្ជើញមកមើលពេលម៉ោងលេង និងចូលក្នុងថ្នាក់ ដើម្បីសង្កេតមើលល្បែងរបស់កូនៗគាត់កាន់តែជិត។ អ្នកដឹកនាំសកម្មភាពអាចអញ្ជើញឪពុកម្តាយ ឲ្យសង្កេតមើលភាពសម្បូរបែបនៃការរាវរករបស់កូនៗគាត់ សមត្ថភាពច្នៃប្រឌិត ប្តូរយោបល់ ចចារ ធ្វើផែនការ ផ្តើមធ្វើ ផ្លាស់កន្លែង រាប់... ធ្វើជាមនុស្សធំដោយសេរីលេងសប្បាយ!



# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី? (ត)

សេចក្តីអញ្ជើញឪពុកម្តាយនេះ មានគោលបំណងបី៖

- ក្នុងពេលម៉ោងល្បែងកុមារបិតនៅក្នុងជំហារ **ទំនុកចិត្តចំពោះមុខឪពុកម្តាយ**របស់វា។
- ការសង្កេត ពេលម៉ោងលេង និងភាពរីករាយ ដែលកូនពួកគាត់លេង អាចធ្វើឲ្យពួកគាត់រំភើបខ្លាំងចំពោះល្បែង និង**លើកទឹកចិត្តពួកគាត់ឲ្យផ្តល់ឱកាសឲ្យកូនលេងនៅផ្ទះ**បានកាន់តែច្រើន។
- ការសង្កេតប្រដាប់លេង អាច**ផ្តល់នូវគំនិតបង្កើត ឬទិញល្បែងឲ្យកូនលេងនៅផ្ទះ**តាមដែលអាចធ្វើបាន។

# តើត្រូវធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

## 3. តួនាទីនៅចុងបញ្ចប់នៃពេលសិក្សា

- **រៀបចំទុកដាក់ល្បែងជាមួយកុមារ**

យ៉ាងតិច ជិត៤៥នាទីនៃល្បែង អ្នកដឹកនាំសកម្មភាពឲ្យសញ្ញាទៅក្មេងៗថាល្បែងនឹងចប់ក្នុង**៥នាទី**ទៀត។ ពេលល្បែងត្រូវបានចប់ អ្នកដឹកនាំសកម្មភាព ត្រូវសុំឲ្យកុមារជួយរៀបទុកដាក់ ប្រដាប់ប្រដាលេង។ ការបបួលឲ្យចូលរួមនេះ សំដៅចំពោះកុមារធំៗមុន។ ជាការសំខាន់ ដែលហៅកុមារឲ្យចូលរួមក្នុងការរៀបទុកដាក់ប្រដាប់ប្រដាលេង មានហេតុផលប្រាំ៖

- **កាយវិការទទួលខុសត្រូវរបស់កុមារ** ព្រមទាំងអភិវឌ្ឍស្វ័យភាពរបស់ពួកគេ។
- អាចឲ្យកុមារ គិតថាហិបល្បែងជារបស់ខ្លួន ហើយពិតជា "វត្ថុដ៏មានតម្លៃ" សម្រាប់ពួកគេ។ កុមារមានអារម្មណ៍ថាកាន់តែ**មានទំនុកចិត្ត** ដើម្បីលេងនៅពេលអនាគត។

# តើគ្រូធ្វើអ្វី នៅពេលសិក្សាល្បែងសេរី?(ត)

- ការរៀបទុកដាក់ គឺជាវិធីមួយដែល**សំគាល់ចុងបញ្ចប់នៃពេលម៉ោងលេង** និងជួយកុមារឲ្យឈប់លេងល្បែងដោយស្ងៀមស្ងាត់។

- អាចលើកទឹកចិត្តឲ្យ**កុមារថែរក្សាល្បែងបានកាន់តែល្អ** និងកត់ត្រាសភាពនៃប្រដាប់លេងមួយចំនួន កុមារអាចមានមនសិការដោយខ្លួនគេ លើអំពើដែលបំផ្លាញដោយរបៀបលេងខ្លះ។

ឧទាហរណ៍: ដើរលើឥដ្ឋធ្វើពីកាតុង។

- ទីបញ្ចប់ ការចូលរួមនេះ អាចធ្វើឲ្យការងាររៀបទុកដាក់ កាន់តែ**ងាយស្រួល និងកាន់តែលឿន សម្រាប់អ្នកដឹកនាំសកម្មភាព**។



# តើមានបញ្ហាលំបាកអ្វីខ្លះកើតឡើង នៅពេលសិក្សាល្បែងសេរី?

# ❖ ការលំបាក និងដំណោះស្រាយ

## ❖ កង្វះទីកន្លែង

កង្វះទីកន្លែង នឹងអាចកែបាន យ៉ាងលំបាក។ ដើម្បីសន្សំទីកន្លែង ល្បែងលំហាត់ និងល្បែងមានក្បួនមួយចំនួន អាចដាក់នៅខាងក្រៅ។ ល្បែងផ្សេងទៀតក៏អាចដាក់នៅខាងក្រៅផងដែរ ឲ្យតែមានកន្ទេលផ្លាស្ទិកមួយដាក់ក្រាល។





# ការលំបាក និងដំណោះស្រាយ (ត)

## ❖ ការបាត់សម្ភារៈ

មធ្យោបាយល្អបំផុត នៅពេលបាត់សម្ភារ គឺធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធនៃការស្តុក(មើលនៅខាងមុខ)។ ប្រសិនបើយើងជួបប្រទះការបាត់សម្ភារច្រើន អ្នកដឹកនាំសកម្មភាព អាចទទួចបញ្ជាក់ អំពីការគោរពល្បែងក្នុងពេលចូលលេង មុនពេលចាប់ផ្តើមម៉ោងលេង។

ជាក់ស្តែង អ្នកដឹកនាំសកម្មភាព អាចគូសបញ្ជាក់ថា ហិបល្បែងមិនមែនជាកម្មសិទ្ធិរបស់កុមារម្នាក់ទេ ប៉ុន្តែវាជារបស់កុមារទាំងអស់។ អ្នកដឹកនាំសកម្មភាព អាចទទួលស្គាល់ការជាប់ចិត្តនេះ ធានាកុមារថាវត្ថុនេះ និងពេលលេងនឹងមាននៅសប្តាហ៍ក្រោយទៀត វាមិនទៅបាត់ទេ។ កុមារមានសិទ្ធិនាំយកអនុស្សាវរីយ៍ក្នុងខួរក្បាលវា ប៉ុន្តែមិនមែនប្រដាប់ប្រដាលេងទេ។

ក្នុងពេលនេះត្រូវជៀសវាងចោទប្រកាន់កុមារថា "លួច"។ សញ្ញាណ "លួច" ជារបស់មនុស្សចាស់ ហើយមិនមែនជារឿងត្រូវប្រើ ដើម្បីពណ៌នាចំពោះកុមារអាយុតិចជាង៦ឆ្នាំទេ។



# ការលំបាក និងដំណោះស្រាយ (ត)

❖ **ការធុញថប់ចំពោះល្បែងមួយចំនួន**

ការសង្កេតកុមារ ត្រូវណែនាំអ្នកដឹកនាំសកម្មភាព ក្នុងការពិនិត្យហិបល្បែងឡើងវិញ។ ត្រូវគិតត្រិះរិះពិចារណាដល់ខ្លឹមសារនៃហិបល្បែង សាកល្បងបង្កើនវាដោយល្បែងថ្មីៗយ៉ាងទៀតទាត់តាមដែលអាចធ្វើទៅបាន។ត្រូវណែនាំឲ្យរក្សាប្រដាប់ប្រដាលេងមួយភាគទុកក្នុងហិប ក្នុងពេលម៉ោងលេង ហើយបើអាចធ្វើបាន ធ្វើការវិលជុំក្នុងស្តុកល្បែង(ការផ្លាស់ប្តូរល្បែង)។



# លំហាត់ពិចារណា

- តើសកម្មភាពខាងក្រោមនេះ ជាប្រភេទល្បែងអ្វីខ្លះ? ចូរបញ្ជាក់មូលហេតុ























# សូមអរគុណ!

